ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



# សៀវភៅណែនាំស្តីពី
# យន្តការតាមដាន និងវាយតម្លៃ ប្រព័ន្ធគាំពារសង្គម

ក្រុមប្រឹក្សាជាតិគាំពារសង្គម
២០២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សៀវភៅណែនាំស្តីពី

# យន្តការតាមដាន និងវាយតម្លៃ ប្រព័ន្ធគាំពារសង្គម

ក្រុមប្រឹក្សាជាតិគាំពារសង្គម
២០២១

# មាតិកា


**បញ្ជីតារាង** ..... ៤

**បញ្ជីរូបភាព** ..... ៥

**បញ្ជីអក្សរកាត់** ..... ៦

**អារម្ភកថា** ..... ៧

**សេចក្តីសម្រេចស្តីពីការដាក់ឱ្យអនុវត្តយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម** ..... ៩

**ខ្លឹមសារសង្ខេបប្រតិបត្តិ** ..... ១៧

**ជំពូកទី១ ៖ សេចក្តីផ្តើម** ..... ១៨

១.១ សាវតារ ..... ១៩

១.២ ការតាមដាន និងវាយតម្លៃ ..... ១៩

១.៣ យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ..... ២០

១.៤ តារាងក្របខណ្ឌតក្កភាពនៃយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ..... ២២

១.៥ ក្របខណ្ឌតក្កភាពនៃយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ..... ២៣

១.៥.១ បច្ច័យ ..... ២៣

១.៥.២ គោលការណ៍ ..... ២៣

១.៥.៣ លទ្ធផលចុងក្រោយ ..... ២៣

១.៥.៤ លទ្ធផលក្នុងឆ្នាំ ..... ២៣

១.៥.៥ ធាតុចូល ..... ២៣

១.៦ ការជ្រើសរើសសូចនាករប្រព័ន្ធគាំពារសង្គម ..... ២៣

**ជំពូកទី២ ៖ យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម** ..... ២៤

២.១ សូចនាករកម្រិតបច្ច័យ (IMPACT INDICATORS) ..... ២៨

២.២ សូចនាករកម្រិតគោលការណ៍ (PRINCIPLE INDICATORS) ..... ៣០

២.៣ សូចនាករកម្រិតលទ្ធផលចុងក្រោយ (OUTCOME INDICATORS) ..... ៣២

២.៤ សូចនាករកម្រិតលទ្ធផលក្នុងឆ្នាំ (OUTPUT INDICATORS) ..... ៣៤

២.៥ សូចនាករកម្រិតធាតុចូល (INPUT INDICATORS) ..... ៣៦

**ជំពូកទី៣ ៖ ការបញ្ចូលទិន្នន័យ** ..... ៣៨

៣.១ ទម្រង់នៃការបញ្ចូលទិន្នន័យ ..... ៣៩

៣.២ គុណភាពទិន្នន័យ ..... ៤១

៣.៣ កាលកំណត់នៃការបញ្ចូលទិន្នន័យ ..... ៤១

**ជំពូកទី៤ ៖ តួនាទី និងសូចនាករតាមអង្គភាពរាយការណ៍** ..... ៤២

៤.១ តួនាទីរបស់អង្គភាពរាយការណ៍ ..... ៤៣

៤.២ សូចនាករតាមអង្គភាពរាយការណ៍ ..... ៤៣

៤.២.១ ក្រសួងសុខាភិបាល ..... ៤៤

៤.២.២ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ..... ៤៨

៤.២.៣ ក្រសួងផែនការ ..... ៥៣

៤.២.៤ ក្រសួងអប់រំ យុវជន និងកីឡា ..... ៥៩

៤.២.៥ អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ........ ៦៥
៤.២.៦ បេឡាជាតិសន្តិសុខសង្គម ........ ៦៩
៤.២.៧ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ........ ៨១
៤.២.៨ វិទ្យាស្ថានជាតិសុខភាពសាធារណៈ ........ ៨៤
៤.២.៩ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ........ ៨៧

**ឧបសម្ព័ន្ធ ៖ សំណួរស្ទង់មតិអំពីគុណភាពសេវាសុខាភិបាល ក្នុងអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា** ........ ៩៨

**ឯកសារយោង ៖** ........ ១០០

# បញ្ជីតារាង

តារាងទី១ ៖ ភាពខុសគ្នារវាងការតាមដាន និងវាយតម្លៃ ........ ១៩
តារាងទី២ ៖ ម៉ាទ្រីសសង្ខេបសូចនាករតាមកម្រិត ........ ២៥
តារាងទី៣ ៖ ម៉ាទ្រីសសង្ខេបក្រុមសូចនាករកម្រិតបច្ច័យ ........ ២៨
តារាងទី៤ ៖ ម៉ាទ្រីសសង្ខេបក្រុមសូចនាករកម្រិតគោលការណ៍ ........ ៣០
តារាងទី៥ ៖ ម៉ាទ្រីសសង្ខេបក្រុមសូចនាករកម្រិតលទ្ធផលចុងក្រោយ ........ ៣២
តារាងទី៦ ៖ ម៉ាទ្រីសសង្ខេបក្រុមសូចនាករកម្រិតលទ្ធផលក្នុងឆ្នាំ ........ ៣៤
តារាងទី៧ ៖ ម៉ាទ្រីសសង្ខេបក្រុមសូចនាករកម្រិតធាតុចូល ........ ៣៦
តារាងទី៨ ៖ សូចនាករក្រសួងសុខាភិបាល ........ ៤៤
តារាងទី៩ ៖ សូចនាករក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ........ ៤៨
តារាងទី១០ ៖ សូចនាករក្រសួងផែនការ ........ ៥៣
តារាងទី១១ ៖ សូចនាករក្រសួងអប់រំ យុវជន និងកីឡា ........ ៦០
តារាងទី១២ ៖ សូចនាករអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ........ ៦៥
តារាងទី១៣ ៖ សូចនាករបេឡាជាតិសន្តិសុខសង្គម ........ ៧០
តារាងទី១៤ ៖ សូចនាករគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ........ ៨១
តារាងទី១៥ ៖ សូចនាករវិទ្យាស្ថានជាតិសុខភាពសាធារណៈ ........ ៨៤
តារាងទី១៦ ៖ សូចនាករអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ........ ៨៨
តារាងទី១៧ ៖ កម្រងសំណួរពាក់ព័ន្ធនឹងគុណភាពសេវាសុខាភិបាលដែលស្នើបញ្ចូលក្នុងកម្រងសំណួរ CSES ........ ៩៨
តារាងទី១៨ ៖ កម្រងសំណួរពាក់ព័ន្ធនឹងការទទួលអត្ថប្រយោជន៍ពីកម្មវិធីគាំពារសង្គមដែលស្នើបញ្ចូលក្នុងកម្រងសំណួរ CSES ........ ៩៩

# បញ្ជីរូបភាព


រូបភាពទី១ ៖ ទស្សនវិស័យនៃការអភិវឌ្ឍយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម .............................. ២១
រូបភាពទី២ ៖ ដំណើរការយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ................................................. ២១
រូបភាពទី៣ ៖ ក្របខណ្ឌតក្កភាពនៃយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម (LOGICAL FRAMEWORK) ២២
រូបភាពទី៤ ៖ ក្រុមសូចនាករកម្រិតបច្ច័យ ............................................................................................. ២៨
រូបភាពទី៥ ៖ ក្រុមសូចនាករកម្រិតគោលការណ៍ ................................................................................. ៣០
រូបភាពទី៦ ៖ ក្រុមសូចនាករកម្រិតលទ្ធផលចុងក្រោយ ......................................................................... ៣២
រូបភាពទី៧ ៖ ក្រុមសូចនាករកម្រិតលទ្ធផលក្នុងឆ្នាំ ................................................................................ ៣៤
រូបភាពទី៨ ៖ ក្រុមសូចនាករកម្រិតធាតុចូល ........................................................................................ ៣៦
រូបភាពទី៩ ៖ ផ្ទាំងបញ្ចូលទិន្នន័យ ...................................................................................................... ៣៩
រូបភាពទី១០ ៖ ផ្ទាំងរាយការណ៍ ....................................................................................................... ៤០
រូបភាពទី១១ ៖ ក្រុមសូចនាករក្រសួងសុខាភិបាល ................................................................................ ៤៤
រូបភាពទី១២ ៖ ក្រុមសូចនាករក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ......................................... ៤៨
រូបភាពទី១៣ ៖ ក្រុមសូចនាករក្រសួងផែនការ ...................................................................................... ៥៣
រូបភាពទី១៤ ៖ ក្រុមសូចនាករក្រសួងអប់រំ យុវជន និងកីឡា ................................................................... ៥៩
រូបភាពទី១៥ ៖ ក្រុមសូចនាករអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ..................................... ៦៥
រូបភាពទី១៦ ៖ ក្រុមសូចនាករបេឡាជាតិសន្តិសុខសង្គម ......................................................................... ៦៩
រូបភាពទី១៧ ៖ ក្រុមសូចនាករគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ................................................ ៨១
រូបភាពទី១៨ ៖ ក្រុមសូចនាករវិទ្យាស្ថានជាតិសុខភាពសាធារណៈ ............................................................. ៨៤
រូបភាពទី១៩ ៖ ក្រុមសូចនាករអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ........................................... ៨៧

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ART | Anti-Retroviral Therapy | ឱសថប្រឆាំងមេរោគអេដស៍ |
| CSES | Cambodia Socio-Economic Survey | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា |
| DTP3 | Diphtheria-Tetanus-Pertussis (Third Dose) | វ៉ាក់សាំង ៣ដូស (ដូសទី៣) |
| DQA | Data Quality Assurance | ការធានាគុណភាពទិន្នន័យ |
| GDB | General Department of Budget | អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| GS-NSPC | General Secretariat for the National Social Protection Council | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម |
| HH | Household | គ្រួសារ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoH | Ministry of Health | ក្រសួងសុខាភិបាល |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| MoP | Ministry of Planning | ក្រសួងផែនការ |
| MoSVY | Ministry of Social Affairs, Veterans and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| M&E | Monitoring and Evaluation | ការតាមដាន និងវាយតម្លៃ |
| NIPH | National Institute of Public Health | វិទ្យាស្ថានជាតិសុខភាពសាធារណៈ |
| NCDM | National Committee for Disaster Management | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| NSSF | National Social Security Fund | បេឡាជាតិសន្តិសុខសង្គម |
| NSPPF | National Social Protection Policy Framework | ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម |
| ODID | On Demand ID poor | ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ |
| OOP | Out-Of-Pocket | ចំណាយប្រាក់ហោប៉ៅ |
| PLHIV | People Living with HIV/AIDS | ប្រជាជនដែលមានផ្ទុកវីរុសអេដស៍ |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| TB | Tuberculosis | ជំងឺរបេង |
| UHC | Universal Health Coverage | ប្រព័ន្ធថៃទាំសុខភាពសកល |
| WHO | World Health Organization | អង្គការសុខភាពពិភពលោក |

# អារម្ភកថា

**“ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥”** គឺជាផែនទីបង្ហាញផ្លូវរបស់រាជរដ្ឋាភិបាលក្នុងការដឹកនាំអនុវត្តគោលនយោបាយគាំពារសង្គមនៅកម្ពុជា នៅក្រោមចក្ខុវិស័យរួមគឺការធានាសន្តិសុខប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ ដើម្បីចូលរួមកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាពសង្គម និងរួមចំណែកដល់ការអភិវឌ្ឍធនធានមនុស្សកាន់តែទូលំទូលាយ ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។

ប្រព័ន្ធគាំពារសង្គមកម្ពុជាត្រូវបានចែកចេញជា ២ សសរស្តម្ភ គឺ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។ ប្រព័ន្ធជំនួយសង្គមគ្របដណ្តប់ផ្នែកចំនួន ៤ រួមមាន៖ ការឆ្លើយតបទៅនឹងគ្រោះអាសន្ន ការអភិវឌ្ឍមូលធនមនុស្ស ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសុខុមាលភាពសម្រាប់ប្រជាជនងាយរងគ្រោះ រីឯប្រព័ន្ធសន្តិសុខសង្គមគ្របដណ្តប់ផ្នែកចំនួន ៥ រួមមាន៖ សោធន ការថែទាំសុខភាព ហានិភ័យការងារ ពិការភាព និងនិកម្មភាព។

ក្របខណ្ឌគោលនយោបាយជាតិក៏បានកំណត់ផងដែរអំពីក្របខណ្ឌអភិបាលកិច្ចថ្មីដើម្បីរៀបចំ និងគ្រប់គ្រងប្រព័ន្ធគាំពារសង្គមឱ្យមានសង្គតិភាព តម្លាភាព និងគណនេយ្យភាព ដែលក្នុងនោះការបង្កើត និងដាក់ឱ្យដំណើរការយន្តការតាមដាន និងវាយតម្លៃគឺជាកត្តាចាំបាច់មួយ។ យន្តការតាមដាន និងវាយតម្លៃនេះមានសារៈសំខាន់ក្នុងការធានានូវការសម្រេចបាននូវគោលដៅខាងលើ ក៏ដូចជា ដើម្បីតាមដាននូវវឌ្ឍនភាព និងភាពខ្វះចន្លោះនានានៃដំណើរការគ្រប់គ្រងចាត់ចែងកម្មវិធី ឬរបបគាំពារសង្គមនីមួយៗ។ យន្តការនេះក៏ជាឧបករណ៍ក្នុងការធានានូវប្រតិតុល្យការក្នុងការអនុវត្តកម្មវិធី ឬរបបគាំពារសង្គមនានាផងដែរ។

ផ្អែកលើការចង្អុលបង្ហាញនេះ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមបានទទួលការអនុញ្ញាតឱ្យរៀបចំ និងកសាងយន្តការតាមដាន និងវាយតម្លៃនេះឡើង ដោយឈរលើអភិក្រមសំខាន់ៗ ដែលចាប់ផ្តើមពីការសិក្សាលើឯកសារយុទ្ធសាស្ត្រ គោលនយោបាយជាតិ និងគោលការណ៍ណែនាំនានា ទាំងក្របខណ្ឌជាតិ និងអន្តរជាតិ ដើម្បីកសាងមូលដ្ឋាន មុននឹងធ្វើការពិភាក្សាជាមួយក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ និងទទួលបានការអនុម័តពីក្រុមប្រឹក្សាជាតិគាំពារសង្គមនាកិច្ចប្រជុំថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០។

យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គមនេះនឹងជួយសម្រួលដល់ការប្រមូលទិន្នន័យ និងព័ត៌មានសម្រាប់ការវិភាគ និងតាមដានវឌ្ឍនភាព និងលទ្ធផលនៃការអនុវត្តរាល់សមាសធាតុនៃប្រព័ន្ធគាំពារសង្គម ដោយផ្តោតលើសូចនាករលទ្ធផលសំខាន់ៗពាក់ព័ន្ធនឹងការពង្រីកវិសាលភាព, ប្រសិទ្ធភាព និងគុណភាពសេវាកម្ម, ការទទួលបានអត្ថប្រយោជន៍ និងការថែទាំសុខភាព, ការវិនិយោគ និងលទ្ធផលប្រៀបធៀបនឹងការវិនិយោគ រួមទាំងសូចនាករលទ្ធផលជាក់លាក់ផ្សេងៗដែលចាំបាច់។

សមាសធាតុសំខាន់ចំនួនបីសម្រាប់ការដាក់ឱ្យអនុវត្តយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គមរួមមាន៖ (១) សេចក្តីសម្រេចស្តីពីការដាក់ឱ្យអនុវត្តយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ដែលជាបទដ្ឋានគតិយុត្ត ដើម្បីកំណត់អំពីកាតព្វកិច្ច និងគោលការណ៍ក្នុងការអនុវត្តយន្តការ ព្រមទាំងសូចនាករដែលត្រូវរាយការណ៍, (២) សៀវភៅណែនាំស្តីពីយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ដែលកំណត់អំពីក្របខណ្ឌតក្កភាព កម្រិតសូចនាករធាតុចូល លទ្ធផលក្នុងឆ្នាំ លទ្ធផលចុងក្រោយ គោលការណ៍ និងបច្ច័យ, និង (៣) ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការអនុវត្តយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ដើម្បីសម្រួលដល់ការងារបញ្ចូលទិន្នន័យ ការគណនា និងការបង្ហាញលទ្ធផលជាក់ស្តែងនៃសូចនាករនីមួយៗ។

យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គមនេះ គឺជាយន្តការរស់ និងមានភាពបត់បែនទៅតាមវឌ្ឍនភាពនៃការវិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ដែលនឹងត្រូវធ្វើការពិនិត្យ និងកែសម្រួលជាបន្តបន្ទាប់ទៅតាមភាពចាំបាច់ និងពេលវេលាជាក់ស្តែង។

ក្នុងនាមក្រុមប្រឹក្សាជាតិគាំពារសង្គម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមការងារ និងថ្នាក់ដឹកនាំនៃបណ្តាក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធដែលបានផ្តល់កិច្ចសហការ និងធាតុចូលសំខាន់ៗសម្រាប់ការរៀបចំយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គមនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះគម្រោង HP+ ដែលគាំទ្រដោយទីភ្នាក់ងារ USAID ក៏ដូចជាដៃគូអភិវឌ្ឍន៍ដទៃទៀត រួមទាំងមូលនិធិសហប្រជាជាតិដើម្បីកុមារ (UNICEF) ដែលបានផ្តល់ការគាំទ្រក្នុងការរៀបចំយន្តការនេះ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០៧៥.....សហវ.......

SOCIAL PROTECTION IN CAMBODIA

# សេចក្តីសម្រេច
## ស្តីពី
## ការដាក់ឱ្យអនុវត្តយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញសេចក្តីសម្រេចលេខ ០០៣ សហវ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- យោងតាមការចាំបាច់របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

សេចក្តីសម្រេចនេះមានគោលបំណងបង្កើត និងដាក់ឱ្យអនុវត្តយន្តការតាមដាន និងវាយតម្លៃ ដើម្បីលើកកម្ពស់ និងបង្កើនប្រសិទ្ធភាព នៃការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ដោយកំណត់វិធាន និងនីតិវិធី នៃការអនុវត្តយន្តការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីនានានៃប្រព័ន្ធគាំពារសង្គម។

**ប្រការ២ .-**

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះក្រសួង-ស្ថាប័ន ដែលមានសកម្មភាពពាក់ព័ន្ធទៅនឹងប្រព័ន្ធគាំពារសង្គមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២
## ស្ថាប័នសម្របសម្រួល

**ប្រការ៣ .-**

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមមានសមត្ថកិច្ចសម្របសម្រួលការអនុវត្តយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ដើម្បីគាំទ្រក្រុមប្រឹក្សាជាតិគាំពារសង្គមក្នុងការតាមដាន ត្រួតពិនិត្យការអនុវត្ត និងវាយតម្លៃវឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម។

**ប្រការ៤ .-**

ក្នុងការអនុវត្តយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា-ជាតិគាំពារសង្គម ក្នុងនាមជាស្ថាប័នសម្របសម្រួល មានតួនាទីដូចខាងក្រោម÷

- អភិវឌ្ឍន៍ប្រព័ន្ធតាមដាន និងវាយតម្លៃ ដែលរួមបញ្ចូលនូវយន្តការ សូចនាករ ការណែនាំអនុវត្ត និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងឯកសារពាក់ព័ន្ធ
- គ្រប់គ្រងប្រតិបត្តិការនៃប្រព័ន្ធតាមដាន និងវាយតម្លៃ និងធ្វើបច្ចុប្បន្នភាពតាមការចាំបាច់
- ប្រមូលទិន្នន័យពីអង្គភាពរាយការណ៍ ដូចមានក្នុងប្រការ៥ នៃសេចក្តីសម្រេចនេះ
- ពិនិត្យ រៀបចំ និងវិភាគទិន្នន័យទៅតាមសូចនាករនានា
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីគាំពារសង្គមនានា និងវឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ជូនគណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ជំពូកទី ៣
## តួនាទី និងភារកិច្ចរបស់អង្គភាពរាយការណ៍

**ប្រការ៥ .-**

ក្រសួង-ស្ថាប័ន ដែលជាអង្គភាពរាយការណ៍មានដូចខាងក្រោម÷

- ក្រសួងសុខាភិបាល

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងផែនការ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បេឡាជាតិសន្តិសុខសង្គម
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- វិទ្យាស្ថានជាតិសុខភាពសាធារណៈ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

ក្រុមប្រឹក្សាជាតិគាំពារសង្គមអាចសម្រេចបន្ថែមក្រសួង-ស្ថាប័នពាក់ព័ន្ធធ្វើជាអង្គភាពរាយការណ៍ទៅតាមការវិវត្តជាក់ស្តែងនៃការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម និងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម។

**ប្រការ៦ .-**

អង្គភាពរាយការណ៍មានកាតព្វកិច្ចផ្តល់ព័ត៌មាន និងទិន្នន័យទៅតាមសូចនាករ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

អង្គភាពរាយការណ៍ត្រូវមានការទទួលខុសត្រូវលើភាពត្រឹមត្រូវ ពេញលេញ និងគុណភាពនៃព័ត៌មាន និងទិន្នន័យដែលរាយការណ៍។

អង្គភាពរាយការណ៍ ត្រូវកំណត់គោលដៅប្រចាំឆ្នាំនៃសូចនាករនីមួយៗ ដើម្បីអាចវាស់វែងការអនុវត្តគោលនយោបាយ និងកម្មវិធីនៃប្រព័ន្ធគាំពារសង្គម។

**ប្រការ៧ .-**

អង្គភាពរាយការណ៍ត្រូវចាត់តាំងជនបង្គោល ដើម្បីសម្របសម្រួល បញ្ជូនព័ត៌មាន និងបញ្ចូលទិន្នន័យក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការតាមដាន និងវាយតម្លៃ។

ជនបង្គោលនៅតាមអង្គភាពរាយការណ៍ មានតួនាទីគ្រប់គ្រងគណនី និងលេខសម្ងាត់ដើម្បីចូលប្រើប្រាស់ប្រព័ន្ធដែលផ្តល់ជូនដោយស្ថាប័នសម្របសម្រួល។

ទិន្នន័យដែលជនបង្គោលបានបញ្ចូលក្នុងប្រព័ន្ធត្រូវចាត់ទុកជាទិន្នន័យផ្លូវការ។ ក្នុងករណីអង្គភាពរាយការណ៍មានបំណងកែសម្រួលទិន្នន័យដែលបានបញ្ចូលរួច អង្គភាពរាយការណ៍ត្រូវធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកស្ថាប័នសម្របសម្រួល ក្នុងរយៈពេល ២ (ពីរ) សប្តាហ៍ យ៉ាងយូរ គិតចាប់ពីថ្ងៃដែលទិន្នន័យត្រូវបានបញ្ចូលក្នុងប្រព័ន្ធ។

**ប្រការ៨ .-**

អង្គភាពរាយការណ៍មានរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីការបញ្ចប់វដ្តនៃរបបរាយការណ៍នីមួយៗ ដើម្បីបញ្ចូលព័ត៌មាន និងទិន្នន័យទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

ក្នុងករណីមិនអាចបំពេញកាតព្វកិច្ចរាយការណ៍ដូចបានកំណត់ខាងលើ អង្គភាពរាយការណ៍ត្រូវជូន

ដំណឹងជាលាយលក្ខណ៍អក្សរ និងបញ្ជាក់ពីមូលហេតុនៃការមិនអាចបំពេញកាតព្វកិច្ចបាន ជូនក្រុមប្រឹក្សា-ជាតិគាំពារសង្គម។

## ជំពូកទី ៤
## ការធ្វើបច្ចុប្បន្នភាពសូចនាករ និងការបញ្ចូលព័ត៌មាន និងទិន្នន័យ

**ប្រការ៩ .-**

ស្ថាប័នសម្របសម្រួលអាចពិនិត្យ និងស្នើសុំក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីធ្វើបច្ចុប្បន្នភាពសូចនាករ ទៅតាមភាពចាំបាច់នៃការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម និងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម។

**ប្រការ១០ .-**

អង្គភាពរាយការណ៍ត្រូវបញ្ចូលព័ត៌មាន និងទិន្នន័យទៅតាមវដ្តនៃរបបរាយការណ៍ ដោយគិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ១១ .-**

រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អនុប្រធាន សមាជិក នៃក្រុមប្រឹក្សាជាតិគាំពារ-សង្គម ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម និងអគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ១១ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ១១ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ
## តារាងសូចនាករតាមក្រសួង-ស្ថាប័នជាអង្គភាពរាយការណ៍

| អង្គភាពរាយការណ៍ | លេខកូដសូចនាករ | ឈ្មោះសូចនាករ |
|---|---|---|
| ក្រសួងសុខាភិបាល | P-07 | - ភាគរយការទូទាត់ក្នុងរយៈពេល ១៥ ថ្ងៃ |
| | OP-01 | - ចំនួនប្រជាជនចុះឈ្មោះថ្មី |
| | OP-05 | - ចំនួនប្រជាជនមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលតាវកាលិក |
| | OP-09 | - ចំនួនថ្ងៃក្នុងការទូទាត់ |
| | OP-10 | - កម្រិតពេញចិត្តរបស់អ្នកជំងឺ |
| | OP-11 | - កម្រិតគុណភាពនៃការផ្តល់សេវាសុខាភិបាល |
| | OP-12 | - កម្រិតគុណភាពនៃការគ្រប់គ្រងមូលដ្ឋានសុខាភិបាល |
| | OP-14 | - ចំនួនករណីពិគ្រោះសុខភាព |
| | OP-15 | - ចំនួនប្រជាជនទទួលបានតាវកាលិក |
| | OP-17 | - ចំនួនថវិកាតាវកាលិកបានផ្ទេរ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | P-01 | - ចំណាយជាក់ស្តែងធៀបនឹងថវិកាគ្រោង |
| | P-04 | - ចំណាយផ្នែករដ្ឋបាល និងចំណាយសរុប |
| | OP-01 | - ចំនួនប្រជាជនចុះឈ្មោះថ្មី |
| | OP-02 | - ចំនួនប្រជាជនឈប់ទទួលបានតាវកាលិក |
| | OP-05 | - ចំនួនប្រជាជនមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលតាវកាលិក |
| | OP-09 | - ចំនួនថ្ងៃក្នុងការទូទាត់ |
| | OP-15 | - ចំនួនប្រជាជនទទួលបានតាវកាលិក |
| | OP-17 | - ចំនួនថវិកាតាវកាលិកបានផ្ទេរ |
| ក្រសួងផែនការ | G-01 | - ចំនួនប្រជាជនក្នុងគ្រួសារក្រីក្រ |
| | G-02 | - អត្រាភាពក្រីក្រ |
| | G-03 | - គម្លាតភាពក្រីក្រ |
| | G-04 | - សន្ទស្សន៍នៃភាពក្រីក្ររបស់កុមារផ្អែកលើសមាសភាពចម្រុះ |
| | G-05 | - ភាគរយនៃប្រជាជនក្រោមបន្ទាត់ភាពងាយរងគ្រោះ |

| | | |
|---|---|---|
| | G-06 | - ភាគរយនៃកំណើនទ្រព្យសកម្មគ្រួសារ |
| | G-09 | - ភាគរយនៃគ្រួសារមានបង្គន់អនាម័យផ្ទាល់ខ្លួន |
| | G-10 | - មេគុណ Gini/សន្ទស្សន៍វិសមភាពចំណាយ |
| | G-11 | - ផលធៀប Palma |
| | OP-13 | - កម្រិតនៃការយល់ឃើញលើគុណភាពសេវាសុខភាព |
| | OP-16 | - ភាគរយនៃប្រជាជនដែលអាចទទួលបានសេវាគាំពារសង្គម |
| | IP-08 | - គម្លាតភាពក្រីក្រសរុបរបស់មនុស្សម្នាក់ៗ |
| ក្រសួងអប់រំ យុវជន និងកីឡា | P-01 | - ចំណាយជាក់ស្តែងធៀបនឹងថវិកាគ្រោង |
| | P-04 | - ចំណាយផ្នែករដ្ឋបាល និងចំណាយសរុប |
| | OC-09 | - អត្រាពិតនៃការសិក្សា |
| | OC-10 | - អត្រាបោះបង់ការសិក្សា |
| | OC-11 | - អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា និងមធ្យមសិក្សា |
| | OP-01 | - ចំនួនសិស្សចុះឈ្មោះថ្មីទទួលបានតាវកាលិក |
| | OP-02 | - ចំនួនសិស្សឈប់ទទួលបានតាវកាលិក |
| | OP-03 | - ចំនួនសាលារៀនគោលដៅ |
| | OP-04 | - ចំនួនសាលារៀនទាំងអស់ |
| | OP-05 | - ចំនួនកុមារមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលតាវកាលិក |
| | OP-09 | - ចំនួនថ្ងៃក្នុងការទូទាត់តាវកាលិក |
| | OP-15 | - ចំនួនសិស្សទទួលបានតាវកាលិក |
| | OP-17 | - ចំនួនថវិកាតាវកាលិកបានផ្ទេរ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) | IP-01 | - ថវិកាអនុម័តសម្រាប់សេវាគាំពារសង្គម |
| | IP-02 | - ថវិកាអនុម័តសម្រាប់សេវាសុខាភិបាល |
| | IP-03 | - ថវិកាបានចំណាយសម្រាប់សេវាគាំពារសង្គម |
| | IP-04 | - ថវិកាបានចំណាយសម្រាប់សេវាសុខាភិបាល |
| | IP-05 | - ភាគរយចំណាយថវិកាជាតិលើសេវាសំខាន់ៗ (អប់រំ សុខា-ភិបាល និងគាំពារសង្គម) |
| | IP-06 | - ភាគរយចំណាយថវិកាជាតិលើកម្មវិធីជំនួយសង្គម ធៀបនឹងផលិតផលក្នុងស្រុកសរុប |
| បេឡាជាតិសន្តិសុខសង្គម | P-01 | - ចំណាយជាក់ស្តែងធៀបនឹងថវិកាគ្រោង |
| | P-04 | - ចំណាយផ្នែករដ្ឋបាល និងចំណាយសរុប |
| | P-07 | - ភាគរយការទូទាត់ក្នុងរយៈពេល ១៥ ថ្ងៃ |
| | P-12 | - សមតុល្យថវិកា |

| | | |
|---|---|---|
| | P-13 | - ព្យាករណ៍ភាគទានប្រមូលបាន |
| | P-14 | - ការវាយតម្លៃហានិភ័យ |
| | OP-01 | - ចំនួនសមាជិកចុះឈ្មោះថ្មី |
| | OP-02 | - ចំនួនសមាជិកឈប់ទទួលបានតាវកាលិក |
| | OP-05 | - ចំនួនប្រជាជនមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលតាវកាលិក |
| | OP-06 | - ចំនួនសហគ្រាស |
| | OP-07 | - ចំនួនសហគ្រាសឈប់បង់ភាគទាន |
| | OP-08 | - ចំនួនសហគ្រាសមានលក្ខខណ្ឌគ្រប់គ្រាន់ទទួលបានការគ្របដណ្តប់ |
| | OP-09 | - ចំនួនថ្ងៃក្នុងការទូទាត់ |
| | OP-14 | - ចំនួនករណីពិគ្រោះសុខភាព |
| | OP-15 | - ចំនួនសមាជិកទទួលបានតាវកាលិក |
| | OP-17 | - ចំនួនថវិកាតាវកាលិកបានផ្ទេរ |
| | IP-01 | - ថវិកាបានគ្រោងសម្រាប់សេវាគាំពារសង្គម |
| | IP-02 | - ថវិកាបានគ្រោងសម្រាប់ផ្នែកថែទាំសុខភាព |
| | IP-03 | - ថវិកាបានចំណាយសម្រាប់សេវាគាំពារសង្គម |
| | IP-04 | - ថវិកាបានចំណាយសម្រាប់ផ្នែកថែទាំសុខភាព |
| គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | P-01 | - ចំណាយជាក់ស្តែងធៀបនឹងថវិកាគ្រោង |
| | P-04 | - ចំណាយផ្នែករដ្ឋបាល និងចំណាយសរុប |
| | OP-05 | - ចំនួនប្រជាជនរងផលប៉ះពាល់ដោយគ្រោះមហន្តរាយ |
| | OP-09 | - ចំនួនថ្ងៃក្នុងការផ្តល់តាវកាលិក |
| | OP-15 | - ចំនួនជនរងគ្រោះទទួលតាវកាលិក |
| | OP-17 | - ចំនួនថវិកាតាវកាលិកបានផ្ទេរ |
| វិទ្យាស្ថានជាតិសុខភាព-សាធារណៈ | G-07 | - ភាគរយប្រជាជនចំណាយប្រាក់ហោប៉ៅលើសេវាសុខភាពលើសពី ១០% ២៥% និង៤០%នៃប្រាក់ចំណូលគ្រួសារ |
| | G-08 | - កម្រិតសន្ទស្សន៍នៃការគ្របដណ្តប់សុខភាពជាសកល |
| | OC-01 | - ភាគរយនៃការពេញចិត្តលើវិធីពន្យារកំណើតទំនើប |
| | OC-02 | - ភាគរយស្ត្រីមានផ្ទៃពោះទទួលបានការពិនិត្យសុខភាពមុនសម្រាល ៤លើក ដោយបុគ្គលិកសុខាភិបាល |

| | | |
|---|---|---|
| | OC-03 | - ភាគរយអត្រាគ្របដណ្តប់នៃវ៉ាក់សាំង ៣ដូស បង្ការជំងឺខាន់ស្លាក់ ក្អកមាន់ តេតាណូស រលាកស្លួត និងរលាកថ្លើមប្រភេទ B |
| | OC-04 | - ភាគរយកុមារក្រោម ៥ឆ្នាំមានជំងឺរលាកសួតបានទទួលការព្យាបាលដោយថ្នាំផ្សះត្រឹមត្រូវនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ |
| | OC-05 | - ចំនួនអ្នកកើតជំងឺរបេងដែលបានរាយការណ៍ និងព្យាបាល |
| | OC-06 | - ចំនួនអ្នកទទួលបានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ |
| | OC-07 | - ភាគរយនៃប្រជាជនមានជំងឺលើសសំពាធឈាមទទួលបានការព្យាបាល |
| | OC-08 | - ភាគរយនៃប្រជាជនមានជំងឺទឹកនោមផ្អែមទទួលបានការព្យាបាល |
| អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម | G-12 | - ភាគរយសមភាពយេនឌ័រក្នុងការចុះឈ្មោះ |
| | G-13 | - ភាគរយសមភាពយេនឌ័រទទួលបានតាវកាលិក |
| | G-14 | - ភាគរយសមភាពចុះឈ្មោះតាមតំបន់ |
| | G-15 | - ភាគរយសមភាពទទួលបានតាវកាលិកតាមតំបន់ |
| | P-02 | - ចំនួនសវនកម្មកម្មវិធី |
| | P-03 | - ចំនួនលទ្ធផលសវនកម្មកម្មវិធីសំខាន់ៗ |
| | P-05 | - ចំណាយលើអត្ថគាហកម្នាក់ |
| | P-06 | - ផលធៀបលទ្ធផលទទួលបានពីថវិកាចំណាយ |
| | P-08 | - ភាគរយប្រជាជនយល់ពីលក្ខខណ្ឌទទួលបានតាវកាលិក |
| | P-09 | - ព័ត៌មានពីថវិកាចំណាយ និងសមិទ្ធកម្មដែលបានបង្ហាញជាសាធារណៈ |
| | P-10 | - ចំនួនការចុះត្រួតពិនិត្យ |
| | P-11 | - កម្រិតពេញចិត្តរបស់អត្ថគាហក |
| | OC-12 | - ចំនួនថ្ងៃផលិតភាពទទួលបាន |
| | OC-13 | - មធ្យមភាគនៃកំណើនផលិតភាព / មធ្យមភាគនៃចំនួនតាវកាលិកបានផ្ទេរ |
| | OC-14 | - អត្រាផ្លាស់ប្តូរថ្លៃស្បៀង |
| | IP-07 | - សន្ទស្សន៍មូលដ្ឋានអប្បបរមានៃកិច្ចគាំពារសង្គម |

# ខ្លឹមសារសង្ខេបប្រតិបត្តិ

“យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម” ត្រូវបានរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់ និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ដែលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាពសង្គម។ សៀវភៅណែនាំស្តីពី “យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម” នេះ ពិពណ៌នាអំពីយន្តការតាមដាន និងវាយតម្លៃ និងលើកកម្ពស់ការយល់ដឹងអំពីសូចនាករគាំពារសង្គម និយមន័យ តួនាទី និងការទទួលខុសត្រូវរបស់អង្គភាពរាយការណ៍ ដើម្បីឱ្យយន្តការនេះ ត្រូវបានអនុវត្តស្របតាមគោលការណ៍ និងការកំណត់នានា និងទទួលបានការសម្រេចដោយក្រុមប្រឹក្សាជាតិគាំពារសង្គម។ សៀវភៅនេះនឹងជួយសម្រួលដល់ការងារតាមដាន និងវាយតម្លៃ ដែលឆ្លុះបញ្ចាំងពីប្រសិទ្ធភាព តម្លាភាព និងស័ក្តិសិទ្ធិភាពនៃការវិនិយោគក្នុងប្រព័ន្ធគាំពារសង្គម របស់រាជរដ្ឋាភិបាល។ សៀវភៅណែនាំនេះ ចែកចេញជា ៤ ជំពូក គឺ ៖

**ជំពូកទី១ សេចក្តីផ្តើម** ពិពណ៌នាអំពីសារតារនៃយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម និងបង្ហាញអំពីតារាងក្របខណ្ឌតក្កភាពនៃយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម និងកម្រិតសូចនាករព្រមទាំងពិពណ៌នាអំពីដំណើរការជ្រើសរើសសូចនាករជាដើម។

**ជំពូកទី២ យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម** សង្ខេបអំពីចង្កោមសូចនាករតាមកម្រិតនីមួយៗ រួមមាន សូចនាករបច្ច័យ សូចនាករគោលការណ៍ សូចនាករលទ្ធផលចុងក្រោយ សូចនាករលទ្ធផលក្នុងឆ្នាំ សូចនាករធាតុចូល ក៏ដូចជាការចាត់ថ្នាក់សូចនាករទៅតាមកម្រិតក្រុម និងទៅតាមអង្គភាពរាយការណ៍ ព្រមទាំងគោលបំណងក្នុងការជ្រើសរើសសូចនាករនីមួយៗ។

**ជំពូកទី៣ ការបញ្ចូលទិន្នន័យ** បង្ហាញអំពីរបៀប និងទម្រង់នៃការបញ្ចូលទិន្នន័យការធានាគុណភាពទិន្នន័យ និងកាលកំណត់នៃការបញ្ចូលទិន្នន័យ។

**ជំពូកទី៤ តួនាទី និងសូចនាករតាមអង្គភាពរាយការណ៍** ផ្តល់ព័ត៌មានអំពីតួនាទី និងសូចនាករតាមអង្គភាពរាយការណ៍ ក៏ដូចជាពិពណ៌នាលម្អិតបន្ថែមអំពីសូចនាករនីមួយៗ ដែលរួមមាន និយមន័យ ការបែងចែក គោលបំណង និងរង្វាយការណ៍ជាដើម។ សូចនាករទាំងនេះ ធានាបាននូវសង្គតិភាពក្នុងការរាយការណ៍ ក៏ដូចជាភាពស៊ីសង្វាក់គ្នារវាងកម្មវិធី ឬរបបនីមួយៗ ក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម។



# ជំពូកទី១
# សេចក្តីផ្តើម

## ជំពូកទី១

# សេចក្តីផ្តើម

## ១.១ សាវតារ

ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ គឺជាឯកសារគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តកម្មវិធីគាំពារសង្គម ក្នុងគោលដៅកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព ព្រមទាំងរួមចំណែកដល់ការអភិវឌ្ឍ និងការគាំពារធនធានមនុស្សឱ្យកាន់តែទូលំទូលាយ និងជំរុញកំណើនសេដ្ឋកិច្ច តាមរយៈសសរស្តម្ភសំខាន់ចំនួន ២ គឺ ៖ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។

ប្រព័ន្ធជំនួយសង្គមផ្តោតលើធាតុផ្សំផ្សេងៗគ្នា ដែលរួមមាន៖ ការឆ្លើយតបទៅនឹងគ្រោះអាសន្ន ការអភិវឌ្ឍមូលធនមនុស្ស ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសុខុមាលភាព សម្រាប់ប្រជាជនងាយរងគ្រោះ។ ដោយឡែក ប្រព័ន្ធសន្តិសុខសង្គមផ្តោតជាពិសេសលើផ្នែកប្រាក់សោធន ការថែទាំសុខភាព ហានិភ័យការងារ និកម្មភាព និងពិការភាព។

ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមនេះ បានទទួលការអនុម័តក្នុងសម័យប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧។ ដើម្បីអនុវត្តក្របខណ្ឌគោលនយោបាយនេះ ក្រុមប្រឹក្សាជាតិគាំពារសង្គមត្រូវបាន បង្កើតឡើងដោយមានគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋានជាសេនាធិការ ទទួលខុសត្រូវលើការតាមដាន និងវាយតម្លៃលើការអនុវត្ត ក៏ដូចជាវឌ្ឍនភាពនៃប្រព័ន្ធគាំពារសង្គមជារួម។

## ១.២ ការតាមដាន និងវាយតម្លៃ

ការតាមដាន និងវាយតម្លៃ គឺជាដំណើរការនៃការប្រមូលទិន្នន័យ និងព័ត៌មានសូចនាករពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី ឬរបបនីមួយៗ ដែលត្រូវបញ្ចូលទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការវិភាគលទ្ធផល និងបង្កើតគោលនយោបាយ។ ការតាមដានជាដំណើរការនៃការពិនិត្យលើធាតុចូល និងលទ្ធផលក្នុងឆ្នាំ ដែលត្រូវការប្រមូល និងប្រើប្រាស់ព័ត៌មាននិងទិន្នន័យទៅតាមចង្កោមសូចនាករ ជាប្រចាំ តាមវដ្តរាយការណ៍ដែលបានកំណត់ ពាក់ព័ន្ធនឹងកម្មវិធី ឬរបបនីមួយៗ។

ការវាយតម្លៃគឺជាការវិភាគលើលទ្ធផលពីការតាមដាន ដើម្បីសន្និដ្ឋានអំពីប្រសិទ្ធភាព និងនិរន្តរភាពលើការអនុវត្តកម្មវិធី ឬរបបនីមួយៗដោយឈរលើការវិភាគជាក់លាក់។សម្រាប់កម្មវិធីឬរបបដែលមានពេលវេលាជាក់លាក់ ការវាយតម្លៃជាទូទៅអាចត្រូវបានធ្វើឡើងនៅពាក់កណ្តាល ឬនៅពេលបញ្ចប់នៃការអនុវត្តកម្មវិធី ឬរបបនីមួយៗ។

**តារាងទី១ ៖ ភាពខុសគ្នារវាងការតាមដាន និងវាយតម្លៃ**

| ការតាមដាន | ការវាយតម្លៃ |
|---|---|
| **ដំណើរការ** | |
| ការសង្កេត និងត្រួតពិនិត្យ | ការវិនិច្ឆ័យ |
| ការបញ្ចូលទិន្នន័យ | ការវិភាគ |
| ការសម្រេចចិត្តប្រចាំថ្ងៃ | ការសម្រេចចិត្តសំខាន់ៗ |
| ផ្តល់ព័ត៌មានសម្រាប់ការវាយតម្លៃ | ផ្តល់ព័ត៌មានសម្រាប់ការធ្វើផែនការយុទ្ធសាស្ត្រ |
| **ពេលណា** | |
| ក្នុងពេលកំពុងអនុវត្ត | មុន ឬក្រោយការអនុវត្ត |
| បន្តអនុវត្តជាប្រចាំ | តាមកាលកំណត់ |

ការតាមដាន និងវាយតម្លៃយ៉ាងទៀងទាត់នៅគ្រប់ដំណាក់កាលនៃការអនុវត្តកម្មវិធី ឬរបបនីមួយៗ នឹងជួយពង្រឹង សម្រួលដល់ការរៀបចំ និងអនុវត្តផែនការឱ្យបានកាន់តែល្អប្រសើរ ចំគោលដៅ ព្រមទាំងធានាឱ្យបាននូវប្រសិទ្ធភាព គណនេយ្យភាព តម្លាភាពនៃការគ្រប់គ្រង និងការប្រតិបត្តិ។

ការតាមដាន និងវាយតម្លៃមានដូចខាងក្រោម៖

- ផ្តល់នូវប្រតិមតិជាប្រចាំទៅលើការអនុវត្តកម្មវិធី ឬរបបនីមួយៗ
- កំណត់បញ្ហាដែលកើតមាន និងផ្តល់អនុសាសន៍លើដំណោះស្រាយ
- តាមដានដំណើរការនៃការអនុវត្ត និងលទ្ធផលនៃកម្មវិធី ឬរបបនីមួយៗ
- វាយតម្លៃទៅលើការសម្រេចបាន ធៀបនឹងគោលដៅនៃកម្មវិធី ឬរបបនីមួយៗ
- វាស់វែងផលប៉ះពាល់នៃកម្មវិធី ឬរបបដោយផ្អែកលើព័ត៌មានពីសូចនាករផ្សេងៗ
- បញ្ចូលទស្សនៈរបស់ភាគីពាក់ព័ន្ធនឹងលើកកម្ពស់ការចូលរួម ភាពជាម្ចាស់ និងគណនេយ្យភាព។

សមាសធាតុសំខាន់ទាំងប្រាំមួយ នៃប្រព័ន្ធតាមដាន និងវាយតម្លៃ៖

- របាយការណ៍ច្បាស់លាស់ពាក់ព័ន្ធការវាស់វែងគោលដៅនៃកម្មវិធី ឬរបបនីមួយៗ
- វចនានុក្រមនៃសូចនាករដែលបានរៀបចំឡើងរួមមាន៖ ធាតុចូល លទ្ធផលក្នុងឆ្នាំ លទ្ធផលចុងក្រោយ គោលការណ៍ និងបច្ច័យ
- យន្តការនៃការប្រមូលទិន្នន័យដែលជួយក្នុងការពិនិត្យវឌ្ឍនភាព រួមទាំងជាមូលដ្ឋាន និងមធ្យោបាយ ដើម្បីប្រៀបធៀបវឌ្ឍនភាព និងសមិទ្ធផលទៅនឹងគោលដៅដែលបានគ្រោងទុក
- ជាមូលដ្ឋានគ្រឹះនៃការប្រមូលទិន្នន័យដោយមានក្របខណ្ឌនៃការវាយតម្លៃ
- យន្តការច្បាស់លាស់សម្រាប់ការរាយការណ៍ និងការប្រើប្រាស់នូវលទ្ធផលដែលបានពីការពិនិត្យ តាមដាន និងវាយតម្លៃក្នុងការធ្វើការសម្រេចចិត្ត
- ការរៀបចំកម្មវិធី ឬរបបប្រកបដោយចីរភាពពឹងផ្អែកលើទិន្នន័យ ការគ្រប់គ្រង ការវិភាគ និងការរាយការណ៍ជាក់លាក់។

## ១.៣ យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម

យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម គឺជាឧបករណ៍វាស់វែងនូវវឌ្ឍនភាព ឆ្ពោះទៅរកការសម្រេចគោលដៅជាតិចម្បង គឺការកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព ក៏ដូចជារួមចំណែកដល់ការអភិវឌ្ឍ និងគាំពារធនធានមនុស្សកាន់តែទូលំទូលាយ និងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងបរិយាប័ន្ន។

យន្តការនេះ បានកំណត់ និងប្រមូលផ្តុំសូចនាករធាតុចូល លទ្ធផលក្នុងឆ្នាំ លទ្ធផលចុងក្រោយ គោលការណ៍ និងបច្ច័យក្នុងប្រព័ន្ធគាំពារសង្គមរួមបញ្ចូលទស្សនវិស័យនានា ដែលរួមមានវិមាត្រគោលនយោបាយគាំពារសង្គម (គោលការណ៍សេដ្ឋកិច្ច-សង្គម និងការបែងចែកឡើងវិញនូវផលប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ច) គោលការណ៍របស់គោលនយោបាយគាំពារសង្គម (អភិបាលកិច្ចល្អ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពចំណាយ ការទទួលខុសត្រូវ និងចីរភាពហិរញ្ញវត្ថុ) និងគោលបំណងនៃគោលនយោបាយគាំពារសង្គម (ពង្រីកការគ្របដណ្តប់ និងបង្កើនប្រសិទ្ធភាព សមធម៌ និងតម្លាភាព)។

យន្តការនេះ តម្រូវឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធកំណត់គោលដៅសម្រាប់សូចនាករនីមួយៗ ស្របតាមផែនការយុទ្ធសាស្ត្ររបស់ក្រសួង-ស្ថាប័ន ដើម្បីធានានូវប្រសិទ្ធភាព ភាពអាចវាស់វែងបានក្នុងការអនុវត្ត និងជាមូលដ្ឋានសម្រាប់គណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិគាំពារសង្គម ធ្វើការវាយតម្លៃលើវឌ្ឍនភាពការងារទាក់ទងនឹងគោលដៅដែលបានកំណត់ក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម។

**រូបភាពទី១ ៖ ទស្សនវិស័យនៃការអភិវឌ្ឍយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម**

### គោលនយោបាយសង្គម

- សង្គម
- សេដ្ឋកិច្ច
- ការបែងចែកឡើងវិញនៃផលប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ច (Wealth redistribution)

### គោលការណ៍គោលនយោបាយគាំពារសង្គម

- អភិបាលកិច្ចល្អ
- ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពចំណាយ
- ការទទួលខុសត្រូវ
- ចីរភាពហិរញ្ញវត្ថុ

### គោលដៅក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម

- បន្ស៊ី និងប្រមូលផ្តុំសមាសធាតុគាំពារសង្គម
- ពង្រីកវិសាលភាពគ្របដណ្តប់
- ពង្រឹងប្រសិទ្ធភាព សមធម៌ និងតម្លាភាព

យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គមប្រើប្រាស់វិធីសាស្ត្របរិមាណវិស័យ និងគុណវិស័យ ដើម្បីចងក្រងទិន្នន័យដូចជា ស្ថិតិសេវា តារាកាលិក ថវិកា ចំណាយ ក៏ដូចជាទិន្នន័យនៃការទូទាត់រដ្ឋបាល។ ទិន្នន័យទាំងអស់នឹងត្រូវបានប្រើប្រាស់សម្រាប់ការវិភាគ និងគណនាជាច្រើនដូចជា ផលធៀបចំណាយរដ្ឋបាល និងតារាកាលិក ថ្លៃចំណាយសម្រាប់អត្ថគាហកម្នាក់ក្នុងកម្មវិធី ឬរបបនីមួយៗ។ល។ ក្នុងនោះ ការធ្វើសង្កេតគ្រួសារថ្នាក់ជាតិ ដែលរួមមាន អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា និងអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា នឹងជំរុញឱ្យមានការវាយតម្លៃសូចនាករពាក់ព័ន្ធនឹងការកាត់បន្ថយភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព។

**រូបភាពទី២ ៖ ដំណើរការយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម**



## ១.៤ ក្របខណ្ឌតក្កភាពនៃយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម

ក្របខណ្ឌតក្កភាពនៃយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម គឺជាឧបករណ៍បង្ហាញពីសម្មតិកម្ម និងទ្រឹស្តីដោយកំណត់សូចនាករចាប់ផ្តើមពីធាតុចូល រហូតដល់ការសម្រេចលទ្ធផលចុងក្រោយ។ ក្របខណ្ឌតក្កភាពនេះ គឺជាមូលដ្ឋានសម្រាប់ការពិនិត្យ និងវាយតម្លៃដោយមានរចនាសម្ព័ន្ធសម្រាប់ការវាស់វែងគ្រប់សូចនាករ ដើម្បីសម្រេចបានគោលបំណងអភិវឌ្ឍន៍។

រូបភាពទី៣ បង្ហាញពីដំណាក់កាលក្នុងការសម្រេចគោលបំណងរំពឹងទុកនៃសមាសធាតុក្នុងកម្មវិធីជាតិគាំពារសង្គម របស់រាជរដ្ឋាភិបាល។ រូបភាពនេះ បង្ហាញពីលំហូរនៃការអនុវត្តសម្រាប់គ្រប់សមាសធាតុនៃកម្មវិធីជាតិគាំពារសង្គម ដោយមានការវាយតម្លៃលើវឌ្ឍនភាព ក្នុងការសម្រេចបាននូវលទ្ធផលចុងក្រោយ ក៏ដូចជាការប្រៀបធៀបការអនុវត្តតាមកម្មវិធី ឬរបបនីមួយៗ និងការវិនិយោគក្នុងប្រព័ន្ធគាំពារសង្គម។

**រូបភាពទី៣ ៖ ក្របខណ្ឌតក្កភាពនៃយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម** (LOGICAL FRAMEWORK)



## ១.៥ ក្របខណ្ឌតក្កភាពនៃយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម

### ១.៥.១ បច្ច័យ

បច្ច័យនៃក្របខណ្ឌតក្កភាពនេះ គឺជាលទ្ធផលចុងក្រោយបំផុតនៃកម្មវិធី ដែលជាមូលដ្ឋានក្នុងការវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី ឬគោលនយោបាយដែលបានផ្តួចផ្តើមឡើងក្នុងបរិការណ៍នៃការកាត់បន្ថយភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព។

### ១.៥.២ គោលការណ៍

គោលការណ៍នៃក្របខណ្ឌតក្កភាពនេះ គឺជាការវាស់វែងលើការអនុវត្តចំណាយប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព អភិបាលកិច្ចល្អ ការទទួលខុសត្រូវ និងចីរភាពហិរញ្ញវត្ថុ។

### ១.៥.៣ លទ្ធផលចុងក្រោយ

លទ្ធផលចុងក្រោយ ឆ្លុះបញ្ចាំងនូវលទ្ធផលសម្រេចបានពីមួយឆ្នាំទៅមួយឆ្នាំ ក្រោយពីការអនុវត្តបានពេញលេញនូវកម្មវិធី ឬរបប ក្នុងរយៈពេលកំណត់ណាមួយ។ ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី បានទៅដល់ប្រជាជនគោលដៅ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខាភិបាល ការអភិវឌ្ឍមូលធនមនុស្ស ផលិតភាព និងស្ថានភាពសេដ្ឋកិច្ចគ្រួសារ។

### ១.៥.៤ លទ្ធផលក្នុងឆ្នាំ

លទ្ធផលក្នុងឆ្នាំ សំដៅលើលទ្ធផលដែលអាចវាស់វែងបានក្នុងឆ្នាំ ក្រោយពីការអនុវត្តកម្មវិធី ឬរបប។ លទ្ធផលភ្លាមៗនៃការអនុវត្តកម្មវិធីពាក់ព័ន្ធនឹងការផ្តល់សេវាដោយផ្ទាល់នៃសមាសធាតុកម្មវិធី និងកម្មវិធី ឬរបបដូចជាចំនួនប្រជាជនចុះឈ្មោះ និងមានលក្ខខណ្ឌគ្រប់គ្រាន់ទទួលបានតាវកាលិក រយៈពេលទូទាត់តាវកាលិក ចំនួនប្រជាជនទទួលបានតាវកាលិក និងចំនួនថវិកាតាវកាលិកបានផ្ទេរ។

### ១.៥.៥ ធាតុចូល

ធាតុចូល សំដៅលើធនធានហិរញ្ញវត្ថុដែលវិនិយោគដើម្បីទទួលបានលទ្ធផល ក្នុងនោះរួមមានចំនួនធនធានដែលបានគ្រោងទុក និងចំនួនដែលបានចំណាយ ដូចជាចំណាយរដ្ឋបាល ចំណាយប្រតិបត្តិការ និងថវិកាតាវកាលិកដែលបានផ្ទេរដោយផ្ទាល់។ ធាតុចូលត្រូវរាយការណ៍តាមកម្រិតអ្នកទទួលផល ភាគទាន និយោជិត និងវិភាគទានរបស់រាជរដ្ឋាភិបាល។

## ១.៦ ការជ្រើសរើសសូចនាករប្រព័ន្ធគាំពារសង្គម

សូចនាករប្រព័ន្ធគាំពារសង្គមត្រូវបានជ្រើសរើសតាមដំណាក់កាលដូចខាងក្រោម៖

១ កំណត់ម៉ាទ្រីសដែលជាតារាងកំណត់សម្គាល់សូចនាករស្របតាមតារាងក្របខណ្ឌតក្កភាព

២ សិក្សា និងពិនិត្យរាល់ឯកសារយុទ្ធសាស្ត្រជាតិ និងផែនការយុទ្ធសាស្ត្ររបស់អង្គភាពរាយការណ៍ ដើម្បីរៀបចំ និងប្រមូលផ្តុំសូចនាករពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គម

៣ សិក្សា និងពិនិត្យអំពីសូចនាករដែលពាក់ព័ន្ធក្នុងប្រព័ន្ធគាំពារសង្គមរបស់ស្ថាប័នអន្តរជាតិ និងដៃគូអភិវឌ្ឍន៍

៤ សិក្សា ប្រជុំពិភាក្សា និងពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ។

គោលបំណងនៃដំណើរការជ្រើសរើសសូចនាករនេះគឺ៖

១ ធានាឱ្យបាននូវការប្រើប្រាស់យន្តការតាមដាន និងវាយតម្លៃដែលមានសូចនាករគ្រប់គ្រាន់ មានសង្គតិភាព និងអាចប្រៀបធៀបបានរាល់កម្មវិធី ឬរបបក្នុងប្រព័ន្ធគាំពារសង្គម

២ កាត់បន្ថយជាអតិបរមានូវរបបរាយការណ៍ និងបន្ទុករបស់អង្គភាពរាយការណ៍។

សូចនាករនឹងត្រូវធ្វើការសិក្សា និងពិនិត្យឡើងវិញជាប្រចាំ។



## ជំពូកទី២

# យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម

## ជំពូកទី២

# យន្តការតាមដាន និងវាយតម្លៃ ប្រព័ន្ធគាំពារសង្គម

យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គមបានប្រមូលផ្តុំព័ត៌មានសូចនាករទៅតាមកម្មវិធី ឬរបបនីមួយៗ ដោយបែងចែកតាមកម្រិត (បច្ច័យ គោលការណ៍ លទ្ធផលចុងក្រោយ លទ្ធផលក្នុងឆ្នាំ និងធាតុចូល) និងក្រុមសូចនាករ។ ទិន្នន័យត្រូវបញ្ចូលចាប់ពីឆ្នាំ២០១៥ ដើម្បីប្រើប្រាស់ជាទិន្នន័យឆ្នាំគោល ក្នុងការកំណត់ជាមូលដ្ឋាននៃការប្រៀបធៀប។

ក្នុងក្របខណ្ឌនៃការសម្របសម្រួលការអនុវត្ត យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម មានតួនាទីដូចខាងក្រោម៖

- អភិវឌ្ឍប្រព័ន្ធតាមដាន និងវាយតម្លៃ ដែលរួមបញ្ចូលនូវយន្តការ សូចនាករ ការណែនាំអនុវត្ត និងប្រព័ន្ធព័ត៌មានវិទ្យា និងឯកសារពាក់ព័ន្ធ
- គ្រប់គ្រងប្រតិបត្តិការនៃប្រព័ន្ធតាមដាន និងវាយតម្លៃ និងធ្វើបច្ចុប្បន្នភាពតាមការចាំបាច់
- ប្រមូលទិន្នន័យពីអង្គភាពរាយការណ៍ ដូចមានក្នុងប្រការ៦ នៃសេចក្តីសម្រេចស្តីពីការដាក់ឱ្យអនុវត្តយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម
- ពិនិត្យ រៀបចំ និងវិភាគទិន្នន័យទៅតាមសូចនាករនានា
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីគាំពារសង្គមនានា ជូនគណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិគាំពារសង្គម។

**តារាងទី២ ៖ ម៉ាទ្រីសសង្ខេបសូចនាករតាមកម្រិត**

| កម្រិត | ក្រុម | លេខកូដ | សូចនាករ |
|---|---|---|---|
| បច្ច័យ | ភាពក្រីក្របានកាត់បន្ថយ | G-01 | ចំនួនប្រជាជនក្នុងគ្រួសារក្រីក្រ |
| | | G-02 | អត្រាភាពក្រីក្រ |
| | | G-03 | គម្លាតភាពក្រីក្រ |
| | | G-04 | សន្ទស្សន៍នៃភាពក្រីក្ររបស់កុមារផ្អែកលើសមាសភាពចម្រុះ |
| | ភាពងាយរងគ្រោះ បានកាត់បន្ថយ | G-05 | ភាគរយនៃប្រជាជនក្រោមបន្ទាត់ភាពងាយរងគ្រោះ |
| | | G-06 | ភាគរយនៃកំណើនទ្រព្យសកម្មគ្រួសារ |
| | | G-07 | ភាគរយប្រជាជនចំណាយប្រាក់ហោប៉ៅលើសេវាសុខភាព លើសពី ១០%, ២៥% និង ៤០% នៃប្រាក់ចំណូលគ្រួសារ |
| | | G-08 | កម្រិតសន្ទស្សន៍នៃការគ្របដណ្តប់សុខភាពជាសកល |
| | | G-09 | ភាគរយនៃគ្រួសារមានបង្គន់អនាម័យផ្ទាល់ខ្លួន |
| | វិសមភាព បានកាត់បន្ថយ | G-10 | មេគុណ Gini/សន្ទស្សន៍វិសមភាពចំណាយ |
| | | G-11 | ផលធៀប Palma |
| | | G-12 | ភាគរយសមភាពយេនឌ័រក្នុងការចុះឈ្មោះ |
| | | G-13 | ភាគរយសមភាពយេនឌ័រទទួលបានការងារកាលិក |
| | | G-14 | ភាគរយសមភាពចុះឈ្មោះតាមតំបន់ |
| | | G-15 | ភាគរយសមភាពទទួលបានការងារកាលិកតាមតំបន់ |

| | | | |
|---|---|---|---|
| គោលការណ៍ | អភិបាលកិច្ចល្អ | P-01 | ចំណាយជាក់ស្ដែងធៀបនឹងថវិកាគ្រោង |
| | | P-02 | ចំនួនសវនកម្មកម្មវិធី |
| | | P-03 | ចំនួនលទ្ធផលសវនកម្មកម្មវិធីសំខាន់ៗ |
| | ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពចំណាយ | P-04 | ចំណាយផ្នែករដ្ឋបាល និងចំណាយសរុប |
| | | P-05 | ចំណាយលើអត្ថគាហកម្នាក់ |
| | | P-06 | ផលធៀបលទ្ធផលទទួលបានពីថវិកាចំណាយ |
| | | P-07 | ភាគរយការទូទាត់ក្នុងរយៈពេល ១៥ ថ្ងៃ |
| | ការទទួលខុសត្រូវ | P-08 | ភាគរយប្រជាជនយល់ពីលក្ខខណ្ឌទទួលបានតាវកាលិក |
| | | P-09 | ព័ត៌មានពីថវិកាចំណាយ និងសមិទ្ធកម្ម ដែលបានបង្ហាញជាសាធារណៈ |
| | | P-10 | ចំនួនការចុះត្រួតពិនិត្យ |
| | | P-11 | កម្រិតពេញចិត្តរបស់អត្ថគាហក |
| | ចីរភាពហិរញ្ញវត្ថុ | P-12 | សមតុល្យថវិកា |
| | | P-13 | ព្យាករណ៍ភាគទានប្រមូលបាន |
| | | P-14 | ការវាយតម្លៃហានិភ័យ |
| លទ្ធផលចុងក្រោយ | ស្ថានភាពសុខាភិបាលបានប្រសើរឡើង | OC-01 | ភាគរយនៃការពេញចិត្តលើវិធីពន្យារកំណើតទំនើប |
| | | OC-02 | ភាគរយស្ត្រីមានផ្ទៃពោះទទួលបានការពិនិត្យសុខភាពមុនសម្រាល ៤ លើក ដោយបុគ្គលិកសុខាភិបាល |
| | | OC-03 | ភាគរយអត្រាគ្របដណ្តប់នៃវ៉ាក់សាំង ៣ដូស បង្ការជំងឺខាន់ស្លាក់ ក្អកមាន់ តេតាណូស រលាកសួត និងរលាកថ្លើមប្រភេទ B |
| | | OC-04 | ភាគរយកុមារក្រោម ៥ ឆ្នាំ មានជំងឺរលាកសួតបានទទួលការព្យាបាលដោយថ្នាំផ្សះត្រឹមត្រូវនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ |
| | | OC-05 | ចំនួនអ្នកកើតជំងឺរបេងដែលបានរាយការណ៍ និងព្យាបាល |
| | | OC-06 | ចំនួនអ្នកទទួលបានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ |
| | | OC-07 | ភាគរយនៃប្រជាជនមានជំងឺលើសសំពាធឈាមទទួលបានការព្យាបាល |
| | | OC-08 | ភាគរយនៃប្រជាជនមានជំងឺទឹកនោមផ្អែមទទួលបានការព្យាបាល |
| | មូលធនមនុស្សបានបន្តអភិវឌ្ឍ | OC-09 | អត្រាពិតនៃការសិក្សា |
| | | OC-10 | អត្រាបោះបង់ការសិក្សា |
| | | OC-11 | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា និងមធ្យមសិក្សា |
| | ផលិតភាពបានកើនឡើង | OC-12 | ចំនួនថ្ងៃផលិតភាពទទួលបាន |
| | ស្ថានភាពសេដ្ឋកិច្ចគ្រួសារបានប្រសើរឡើង | OC-13 | មធ្យមភាគនៃកំណើនផលិតភាព / មធ្យមភាគនៃចំនួនតាវកាលិកបានផ្ទេរ |
| | | OC-14 | អត្រាផ្លាស់ប្តូរថ្លៃស្បៀង |

| | | | |
|---|---|---|---|
| លទ្ធផលក្នុងឆ្នាំ | ការគ្របដណ្ដប់បានពង្រីក | OP-01 | ចំនួនប្រជាជនចុះឈ្មោះថ្មី |
| | | OP-02 | ចំនួនប្រជាជនឈប់ទទួលបានតាវកាលិក |
| | | OP-03 | ចំនួនសាលារៀនគោលដៅ |
| | | OP-04 | ចំនួនសាលារៀនទាំងអស់ |
| | | OP-05 | ចំនួនប្រជាជនមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលតាវកាលិក |
| | | OP-06 | ចំនួនសហគ្រាស |
| | | OP-07 | ចំនួនសហគ្រាសឈប់បង់ភាគទាន |
| | | OP-08 | ចំនួនសហគ្រាសមានលក្ខខណ្ឌគ្រប់គ្រាន់ទទួលបានការគ្របដណ្ដប់ |
| | ប្រសិទ្ធភាព និងគុណភាពសេវាបានប្រសើរឡើង | OP-09 | ចំនួនថ្ងៃក្នុងការទូទាត់តាវកាលិក |
| | | OP-10 | កម្រិតពេញចិត្តរបស់អ្នកជំងឺ |
| | | OP-11 | កម្រិតគុណភាពនៃការផ្ដល់សេវាសុខាភិបាល |
| | | OP-12 | កម្រិតគុណភាពនៃការគ្រប់គ្រងមូលដ្ឋានសុខាភិបាល |
| | | OP-13 | កម្រិតនៃការយល់ឃើញលើគុណភាពសេវាសុខភាព |
| | ការទទួលបានការថែទាំសុខភាព និងអត្ថប្រយោជន៍បានប្រសើរឡើង | OP-14 | ចំនួនករណីពិគ្រោះសុខភាព |
| | | OP-15 | ចំនួនប្រជាជនទទួលបានតាវកាលិក |
| | | OP-16 | ភាគរយនៃប្រជាជនដែលអាចទទួលបានសេវាគាំពារសង្គម |
| | ធនធានគ្រួសារបានកើនឡើង | OP-17 | ចំនួនថវិកាតាវកាលិកបានផ្ទេរ |
| ធាតុចូល | ការវិនិយោគដែលបានគ្រោងទុក | IP-01 | ថវិកាបានគ្រោងសម្រាប់សេវាគាំពារសង្គម |
| | | IP-02 | ថវិកាបានគ្រោងសម្រាប់សេវាសុខាភិបាល |
| | ការវិនិយោគជាក់ស្ដែង | IP-03 | ថវិកាបានចំណាយសម្រាប់សេវាគាំពារសង្គម |
| | | IP-04 | ថវិកាបានចំណាយសម្រាប់សេវាសុខាភិបាល |
| | ការកំណត់អាទិភាព | IP-05 | ភាគរយចំណាយថវិកាជាតិលើសេវាសំខាន់ៗ (អប់រំ សុខាភិបាល និងគាំពារសង្គម) |
| | | IP-06 | ភាគរយចំណាយថវិកាជាតិលើកម្មវិធីជំនួយសង្គមធៀបនឹងផលិតផលក្នុងស្រុកសរុប |
| | គម្លាតវិនិយោគ | IP-07 | សន្ទស្សន៍មូលដ្ឋានអប្បបរមានៃកិច្ចគាំពារសង្គម |
| | | IP-08 | គម្លាតភាពក្រីក្រសរុបរបស់មនុស្សម្នាក់ៗ |

## ២.១ សូចនាករកម្រិតបច្ច័យ (IMPACT INDICATORS)

**រូបភាពទី៤ ៖ ក្រុមសូចនាករកម្រិតបច្ច័យ**




សូចនាករកម្រិតបច្ច័យមានធាតុផ្សំ ៣ ក្រុមធំៗគឺ ៖ (១) ភាពក្រីក្របានកាត់បន្ថយ (២) ភាពងាយរងគ្រោះបានកាត់បន្ថយ និង (៣) វិសមភាពបានកាត់បន្ថយ។ កម្រិតបច្ច័យមានសូចនាករទាំងអស់ចំនួន១៥។

**តារាងទី៣ ៖ ម៉ាទ្រីសសង្ខេបក្រុមសូចនាករកម្រិតបច្ច័យ**

| សូចនាករ | គោលបំណង | ប្រភពទិន្នន័យ | អង្គភាព រាយការណ៍ | វដ្ត រាយការណ៍ |
|---|---|---|---|---|
| **ភាពក្រីក្របានកាត់បន្ថយ (Poverty Reduced)** | | | | |
| ចំនួនប្រជាជនក្នុងគ្រួសារក្រីក្រ | តាមដាននិន្នាការភាពក្រីក្រ | ប្រព័ន្ធទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ | MoP | ប្រចាំឆ្នាំ |
| អត្រាភាពក្រីក្រ | តាមដាននិន្នាការភាពក្រីក្រ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | MoP | ២ឆ្នាំម្តង |
| គម្លាតភាពក្រីក្រ | ស្វែងរកគម្លាតភាពក្រីក្រគិតជាភាគរយនៃប្រាក់ចំណូលរបស់ប្រជាជនក្រីក្រដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | MoP | ២ឆ្នាំម្តង |
| សន្ទស្សន៍នៃភាពក្រីក្ររបស់កុមារផ្អែកលើសមាសភាពចម្រុះ | វាស់លទ្ធភាពរបស់កុមារក្នុងការទទួលបានអាហារ និងសេវាទាំងឡាយដែលជាមូលដ្ឋានគ្រឹះដើម្បីអភិវឌ្ឍ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា (សូចនាករថ្មី) | MoP | រៀងរាល់ ៥ឆ្នាំ |
| **ភាពងាយរងគ្រោះបានកាត់បន្ថយ (Vulnerability Reduced)** | | | | |
| ភាគរយនៃប្រជាជនក្រោមបន្ទាត់ភាពងាយរងគ្រោះ | គណនាភាគរយប្រជាជនងាយរងគ្រោះផ្នែកហិរញ្ញវត្ថុ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | MoP | ២ឆ្នាំម្តង |
| ភាគរយនៃកំណើនទ្រព្យសកម្មគ្រួសារ | គណនាកំណើនទ្រព្យសកម្មនៃគ្រួសារដែលជាកត្តាកំណត់ការកាត់បន្ថយភាពងាយរងគ្រោះផ្នែកហិរញ្ញវត្ថុ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | MoP | ២ឆ្នាំម្តង |

| | | | | |
|---|---|---|---|---|
| ភាគរយប្រជាជនចំណាយប្រាក់ហោប៉ៅលើសេវាសុខភាពលើសពី ១០%, ២៥% និង៤០% នៃប្រាក់ចំណូលគ្រួសារ | គណនាភាគរយប្រជាជនប្រឈមនឹងហានិភ័យនៃភាពក្រីក្រ ដោយមានចំណាយលើសកម្រិតដែលកំណត់ដោយអង្គការសុខភាពពិភពលោកលើសេវាសុខភាព | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | NIPH | ២ឆ្នាំម្តង |
| កម្រិតសន្ទស្សន៍នៃការគ្របដណ្តប់សុខភាពជាសកល | សង្ខេបសូចនាករនៃការគ្របដណ្តប់សេវាថែទាំសុខភាពចម្បងៗ | ស្ថិតិការផ្តល់សេវា | NIPH | ប្រចាំឆ្នាំ |
| ភាគរយនៃគ្រួសារមានបង្គន់អនាម័យផ្ទាល់ខ្លួន | បង្គន់គ្មានអនាម័យជាប្រភពចម្លងជំងឺដែលបណ្តាលឱ្យបាត់បង់ផលិតភាពការងាររបស់ប្រជាជនប្រចាំថ្ងៃ ព្រមទាំងចំណាយលើការព្យាបាល | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | MoP | ២ឆ្នាំម្តង |
| **វិសមភាពបានកាត់បន្ថយ (Inequality Reduced)** | | | | |
| មេគុណ Gini/សន្ទស្សន៍វិសមភាពចំណាយ | វាស់គម្លាតនៃការបែងចែកចំណាយជាក់ស្តែងរបស់បុគ្គល ឬគ្រួសារជាមួយការបែងចែងបែបសមភាព | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | MoP | ២ឆ្នាំម្តង |
| ផលធៀប Palma | ពិនិត្យវិសមភាពប្រាក់ចំណូល | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | MoP | ២ឆ្នាំម្តង |
| ភាគរយសមភាពយេនឌ័រក្នុងការចុះឈ្មោះ | ពិនិត្យសមភាពយេនឌ័រក្នុងការចុះឈ្មោះ | ការគណនា | GS-NSPC | ប្រចាំត្រីមាស |
| ភាគរយសមភាពយេនឌ័រទទួលបានតាវកាលិក | ពិនិត្យសមភាពយេនឌ័រទទួលតាវកាលិក | ការគណនា | GS-NSPC | ប្រចាំត្រីមាស |
| ភាគរយសមភាពចុះឈ្មោះតាមតំបន់ | ពិនិត្យសមភាពចុះឈ្មោះតាមតំបន់ | ការគណនា | GS-NSPC | ប្រចាំត្រីមាស |
| ភាគរយសមភាពទទួលបានតាវកាលិកតាមតំបន់ | ពិនិត្យសមភាពទទួលតាវកាលិកតាមតំបន់ | ការគណនា | GS-NSPC | ប្រចាំត្រីមាស |

## ២.២ សូចនាករកម្រិតគោលការណ៍ (PRINCIPLE INDICATORS)

**រូបភាពទី៥ ៖ ក្រុមសូចនាករកម្រិតគោលការណ៍**




សូចនាករកម្រិតគោលការណ៍មានធាតុផ្សំ ៤ ក្រុមធំៗគឺ ៖ (១) អភិបាលកិច្ចល្អ (២) ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពចំណាយ (៣) ការទទួលខុសត្រូវ និង (៤) ចីរភាពហិរញ្ញវត្ថុ។ សូចនាករកម្រិតគោលការណ៍មានសូចនាករទាំងអស់ចំនួន១៤។

**តារាងទី៤ ៖ ម៉ាទ្រីសសង្ខេបក្រុមសូចនាករកម្រិតគោលការណ៍**

| សូចនាករ | គោលបំណង | ប្រភពទិន្នន័យ | អង្គភាព រាយការណ៍ | វដ្ត រាយការណ៍ |
|---|---|---|---|---|
| **អភិបាលកិច្ចល្អ (Good Governance)** | | | | |
| ចំណាយជាក់ស្តែង ធៀបនឹងថវិកាគ្រោង | កំណត់ផែនការ តម្រូវការ និង/ឬ កំណត់បញ្ហា និងធនធាន ដែលមាន | របាយការណ៍ ចំណាយ | MoSVY, MoEYS, NCDM, NSSF | ប្រចាំត្រីមាស ឬប្រចាំឆ្នាំ |
| ចំនួនសវនកម្មកម្មវិធី | កំណត់បញ្ហា និងវិធានការកែតម្រូវ និងធានាបាននូវរបាយការណ៍ ត្រឹមត្រូវ និងគួរទុកចិត្តបាន | ការធ្វើសវនកម្ម កម្មវិធី | GS-NSPC | ប្រចាំឆ្នាំ |
| ចំនួនលទ្ធផល សវនកម្មកម្មវិធីសំខាន់ៗ | រកដំណោះស្រាយភ្លាមៗ និង កាត់បន្ថយផលវិបាកនានា ដែលអាចកើតមាន | ការធ្វើសវនកម្ម កម្មវិធី | GS-NSPC | ប្រចាំឆ្នាំ |
| **ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពចំណាយ (Effective and Efficient Spending)** | | | | |
| ចំណាយផ្នែករដ្ឋបាល និងចំណាយសរុប | តាមដាន និងវាយតម្លៃប្រសិទ្ធភាព នៃសមិទ្ធកម្មផ្នែករដ្ឋបាល | របាយការណ៍ ចំណាយ | MoSVY, MoEYS, NCDM, NSSF | ប្រចាំឆ្នាំ |
| ចំណាយលើ អត្ថគាហកម្នាក់ | វិភាគស័ក្តិសិទ្ធិភាព ដោយ ប្រៀបធៀបលទ្ធផលពីប្រព័ន្ធ គាំពារសង្គម ទៅនឹងចំណាយ សរុបលើប្រព័ន្ធគាំពារសង្គម | ការគណនា | MoEYS, NCDM, NSSF | ប្រចាំឆ្នាំ |

| | | | | |
|---|---|---|---|---|
| ផលធៀបលទ្ធផលទទួលបានពីថវិកាចំណាយ | ប្រៀបធៀបលទ្ធផលបានពីការវិនិយោគតាមសមាសធាតុកម្មវិធី និងកម្មវិធី ឬរបបនានា ដើម្បីកំណត់អាទិភាពក្នុងការវិនិយោគនាពេលអនាគត | ការគណនា | GS-NSPC | ប្រចាំឆ្នាំ |
| ភាគរយការទូទាត់ក្នុងរយៈពេល ១៥ ថ្ងៃ | លើកកម្ពស់គណនេយ្យភាព និងការផ្តល់តាវកាលិក | ស្ថិតិការផ្តល់សេវា | MoH, NSSF | ប្រចាំត្រីមាស |
| **ការទទួលខុសត្រូវ (Accountability)** | | | | |
| ភាគរយប្រជាជនយល់ពីលក្ខខណ្ឌទទួលបានតាវកាលិក | តាមដានការយល់ដឹងជាសាធារណៈ នៃសិទ្ធិទទួលបានតាវកាលិក | របាយការណ៍បេសកកម្មតាមមូលដ្ឋាន | GS-NSPC | ប្រចាំឆ្នាំ |
| ព័ត៌មានពីថវិកាចំណាយ និងសមិទ្ធកម្មដែលបានបង្ហាញជាសាធារណៈ | ធានាតម្លាភាពនៃការវិនិយោគ និងលទ្ធផលសម្រេចបានពីកិច្ចគាំពារសង្គម និងសុខាភិបាល | ផ្ទាំងព័ត៌មានយន្តការតាមដាន និងវាយតម្លៃ | GS-NSPC | ប្រចាំត្រីមាស |
| ចំនួនការចុះត្រួតពិនិត្យ | ធានាគុណភាពសេវាតាមរយៈប្រតិមតិដោយផ្ទាល់ពីអ្នកផ្តល់សេវា និងអត្ថគាហក | របាយការណ៍បេសកកម្មតាមមូលដ្ឋាន | GS-NSPC | ប្រចាំត្រីមាស |
| កម្រិតពេញចិត្តរបស់អត្ថគាហក | ស្វែងយល់ពីគុណភាពដែលទទួលបានពីសេវាគាំពារសង្គមទាំងឡាយ | របាយការណ៍បេសកកម្មតាមមូលដ្ឋាន | GS-NSPC | ប្រចាំត្រីមាស |
| **ចីរភាពហិរញ្ញវត្ថុ (Financial Sustainability)** | | | | |
| សមតុល្យថវិកា | ពិនិត្យលទ្ធភាពទូទាត់តាវកាលិក នាពេលបច្ចុប្បន្ន និងអនាគត | របាយការណ៍ហិរញ្ញវត្ថុ | NSSF | ប្រចាំត្រីមាស |
| ព្យាករណ៍ភាគទានប្រមូលបាន | ពិនិត្យលទ្ធភាពទូទាត់តាវកាលិក នាពេលបច្ចុប្បន្ន និងអនាគត | របាយការណ៍ហិរញ្ញវត្ថុ | NSSF | ប្រចាំឆ្នាំ |
| ការវាយតម្លៃហានិភ័យ | កំណត់អត្រាភាគទាន និងធ្វើផែនការវឌ្ឍនភាពថវិកា | របាយការណ៍វាយតម្លៃជាក់ស្តែង | NSSF | ៣ឆ្នាំម្តង |

## ២.៣ សូចនាករកម្រិតលទ្ធផលចុងក្រោយ (OUTCOME INDICATORS)

**រូបភាពទី៦ ៖ ក្រុមសូចនាករកម្រិតលទ្ធផលចុងក្រោយ**




សូចនាករកម្រិតលទ្ធផលចុងក្រោយមានធាតុផ្សំ ៤ ក្រុមធំៗគឺ ៖ (១) ស្ថានភាពផ្នែកសុខាភិបាលបានប្រសើរឡើង (២) មូលធនមនុស្សបានអភិវឌ្ឍ (៣) ផលិតភាពបានកើនឡើង និង (៤) ស្ថានភាពសេដ្ឋកិច្ចគ្រួសារបានប្រសើរឡើង។ សូចនាករកម្រិតលទ្ធផលចុងក្រោយមានសូចនាករសរុបទាំងអស់ចំនួន១៤។

**តារាងទី៥ ៖ ម៉ាទ្រីសសង្ខេបក្រុមសូចនាករកម្រិតលទ្ធផលចុងក្រោយ**

| សូចនាករ | គោលបំណង | ប្រភពទិន្នន័យ | អង្គភាពរាយការណ៍ | វដ្តរាយការណ៍ |
|---|---|---|---|---|
| **ស្ថានភាពផ្នែកសុខាភិបាលបានប្រសើរឡើង (Health Status Improved)** | | | | |
| ភាគរយនៃការពេញចិត្តលើវិធីនៃការពន្យារកំណើតទំនើប | តាមដានពីសមាមាត្រផ្តល់សេវាបង្ការចម្បងៗធៀបនឹងតម្រូវការជាក់ស្តែង | ស្ថិតិការផ្តល់សេវា | NIPH | ប្រចាំឆ្នាំ |
| ភាគរយស្ត្រីមានផ្ទៃពោះទទួលបានការពិនិត្យសុខភាពមុនសម្រាល ៤ លើក ដោយបុគ្គលិកសុខាភិបាល | តាមដានពីសមាមាត្រនៃការផ្តល់សេវាបង្ការចម្បងៗធៀបនឹងតម្រូវការជាក់ស្តែង | ស្ថិតិការផ្តល់សេវា | NIPH | ប្រចាំឆ្នាំ |
| ភាគរយអត្រាគ្របដណ្តប់នៃវ៉ាក់សាំង ៣ដូស បង្ការជំងឺខាន់ស្លាក់ ក្អកមាន់ តេតាណូស រលាកសួត និងរលាកថ្លើមប្រភេទ B | តាមដានពីសមាមាត្រនៃការផ្តល់សេវាបង្ការចម្បងៗធៀបនឹងតម្រូវការជាក់ស្តែង | ស្ថិតិការផ្តល់សេវា | NIPH | ប្រចាំឆ្នាំ |
| ភាគរយកុមារក្រោម ៥ឆ្នាំមានជំងឺរលាកសួតបានទទួលការព្យាបាលដោយថ្នាំផ្សះត្រឹមត្រូវនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ | តាមដានពីសមាមាត្រនៃការផ្តល់សេវាបង្ការចម្បងៗធៀបនឹងតម្រូវការជាក់ស្តែង | ស្ថិតិការផ្តល់សេវា | NIPH | ប្រចាំឆ្នាំ |
| ចំនួនអ្នកកើតជំងឺរបេងដែលបានរាយការណ៍ និងព្យាបាល | តាមដានពីសមាមាត្រនៃការផ្តល់សេវាបង្ការចម្បងៗធៀបនឹងតម្រូវការជាក់ស្តែង | ស្ថិតិការផ្តល់សេវា | NIPH | ប្រចាំឆ្នាំ |

| | | | | |
|---|---|---|---|---|
| ចំនួនអ្នកទទួលបានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ | តាមដានពីសមាមាត្រនៃការផ្តល់សេវាបង្ការចម្លងៗធៀបនឹងតម្រូវការជាក់ស្តែង | ស្ថិតិការផ្តល់សេវា | NIPH | ប្រចាំឆ្នាំ |
| ភាគរយនៃប្រជាជនមានជំងឺលើសសំពាធឈាមទទួលបានការព្យាបាល | តាមដានពីសមាមាត្រនៃការផ្តល់សេវាបង្ការចម្លងៗធៀបនឹងតម្រូវការជាក់ស្តែង | ស្ថិតិការផ្តល់សេវា | NIPH | ប្រចាំឆ្នាំ |
| ភាគរយនៃប្រជាជនមានជំងឺទឹកនោមផ្អែមទទួលបានការព្យាបាល | តាមដានពីសមាមាត្រនៃការផ្តល់សេវាបង្ការចម្លងៗធៀបនឹងតម្រូវការជាក់ស្តែង | ស្ថិតិការផ្តល់សេវា | NIPH | ប្រចាំឆ្នាំ |
| **មូលធនមនុស្សបានបន្តអភិវឌ្ឍ (Human Capital Being Developed)** | | | | |
| អត្រាពិតនៃការសិក្សា | វាយតម្លៃសមិទ្ធផលកម្មវិធីផ្តល់អាហារនៅតាមសាលារៀនដោយប្រើកសិផលក្នុងសហគមន៍ និងកម្មវិធីអាហារូបករណ៍សម្រាប់ថ្នាក់បឋមសិក្សា និងមធ្យមសិក្សា | របាយការណ៍ក្រសួងអប់រំ យុវជន និងកីឡា | MoEYS | ប្រចាំឆ្នាំ |
| អត្រាបោះបង់ការសិក្សា | វាយតម្លៃសមិទ្ធផលកម្មវិធីផ្តល់អាហារនៅតាមសាលារៀនដោយប្រើកសិផលក្នុងសហគមន៍ និងកម្មវិធីអាហារូបករណ៍សម្រាប់ថ្នាក់បឋមសិក្សា និងមធ្យមសិក្សា | របាយការណ៍ក្រសួងអប់រំ យុវជន និងកីឡា | MoEYS | ប្រចាំឆ្នាំ |
| អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា និងមធ្យមសិក្សា | វាយតម្លៃសមិទ្ធផលកម្មវិធីផ្តល់អាហារនៅតាមសាលារៀនដោយប្រើកសិផលក្នុងសហគមន៍ និងកម្មវិធីអាហារូបករណ៍សម្រាប់ថ្នាក់បឋមសិក្សា និងមធ្យមសិក្សា | របាយការណ៍ក្រសួងអប់រំ យុវជន និងកីឡា | MoEYS | ប្រចាំឆ្នាំ |
| **ផលិតភាពបានកើនឡើង (Productivity Increased)** | | | | |
| ចំនួនថ្ងៃផលិតភាពទទួលបាន | ប៉ាន់ប្រមាណកំណើនផលិតភាពទទួលបានពីកម្មវិធីគាំពារសង្គមទាំងឡាយ | ការគណនា | GS-NSPC | ប្រចាំឆ្នាំ |
| **ស្ថានភាពសេដ្ឋកិច្ចគ្រួសារបានប្រសើរឡើង (Household Economic Position Improved)** | | | | |
| មធ្យមភាគនៃកំណើនផលិតភាព/មធ្យមភាគនៃចំនួនតាវកាលិកបានផ្ទេរ | ប៉ាន់ប្រមាណស្ថានភាពសេដ្ឋកិច្ចគ្រួសារប្រសើរឡើងដោយសារកម្មវិធីគាំពារសង្គម | ការគណនា | GS-NSPC | ប្រចាំឆ្នាំ |
| អត្រាផ្លាស់ប្តូរថ្លៃស្បៀង | ប៉ាន់ប្រមាណប្រសិទ្ធភាពនៃការធ្វើអន្តរាគមន៍ទៅលើស្ថិរភាពថ្លៃស្បៀង | Live Rice Index | GS-NSPC | ប្រចាំត្រីមាស |

# ២.៤ សូចនាករកម្រិតលទ្ធផលក្នុងឆ្នាំ (OUTPUT INDICATORS)

**រូបភាពទី៧ ៖ ក្រុមសូចនាករកម្រិតលទ្ធផលក្នុងឆ្នាំ**




សូចនាករកម្រិតលទ្ធផលក្នុងឆ្នាំមានធាតុផ្សំ ៤ ក្រុមធំៗគឺ ៖ (១) ការគ្របដណ្តប់បានពង្រីក (២) ប្រសិទ្ធភាព និងគុណភាពសេវាបានប្រសើរឡើង (៣) ការទទួលបានការថែទាំសុខភាព និងអត្ថប្រយោជន៍បានប្រសើរឡើង និង (៤) ធនធានគ្រួសារបានកើនឡើង។ សូចនាករកម្រិតលទ្ធផលក្នុងឆ្នាំមានសូចនាករសរុបទាំងអស់ចំនួន១៧។

**តារាងទី៦ ៖ ម៉ាទ្រីសសង្ខេបក្រុមសូចនាករកម្រិតលទ្ធផលក្នុងឆ្នាំ**

| សូចនាករ | គោលបំណង | ប្រភពទិន្នន័យ | អង្គភាពរាយការណ៍ | វដ្តរាយការណ៍ |
|---|---|---|---|---|
| **ការគ្របដណ្តប់បានពង្រីក (Coverage Expanded)** | | | | |
| ចំនួនប្រជាជនចុះឈ្មោះថ្មី | តាមដានវឌ្ឍនភាពនៃការពង្រីកវិសាលភាពនៃកម្មវិធីនីមួយៗ និងគណនាវិសាលភាពដែលបានគ្របដណ្តប់ | ទិន្នន័យពីការចុះឈ្មោះ | MoH, NSSF, MoSVY, MoEYS | ប្រចាំត្រីមាស ឬប្រចាំឆ្នាំ |
| ចំនួនប្រជាជនឈប់ទទួលបានតាវកាលិក | តាមដានអត្រាបោះបង់សិទ្ធិក្នុងការទទួលបានតាវកាលិក និងគណនាវិសាលភាពដែលបានគ្របដណ្តប់ | ទិន្នន័យពីការចុះឈ្មោះ | NSSF, MoEYS, MoSVY | ប្រចាំត្រីមាស ឬប្រចាំឆ្នាំ |
| ចំនួនសាលារៀនគោលដៅ | តាមដានដំណើរការនៃការពង្រីកវិសាលភាពកម្មវិធី ដើម្បីប្រើសម្រាប់គណនាអត្រាសាលាគោលដៅដែលបានគ្របដណ្តប់ | ទិន្នន័យពីការចុះឈ្មោះ | MoEYS | ប្រចាំឆ្នាំ |
